# មេរៀនទី ១៥០:
# មិត្តភក្តិរបស់ដានីយ៉ែលគេចផុតពីគុកភ្លើងយ៉ាងសន្ធោរសន្ធៅ
## ដានីយ៉ែល ៣

**គោលបំណង៖** ព្រះជួយយើងឲ្យធ្វើនូវរឿងដ៏ត្រឹមត្រូវ បើទោះបីជាវាមើលទៅពិបាកក៏ដោយ។

**ខគម្ពីរចងចាំ៖ រ៉ូម ១២:២១** *“កុំឲ្យសេចក្តីអាក្រក់ឈ្នះអ្នកឡើយ ត្រូវឲ្យអ្នកឈ្នះសេចក្តីអាក្រក់ ដោយសារសេចក្តីល្អវិញ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវអាចយល់បានពីបញ្ហាដែលយើងប្រឈមមុខនៅពេលយើងឈរមាំសម្រាប់ព្រះ ហើយព្រោះព្រះអង្គបានទទួលបទពិសោធន៍ទាំងអស់នេះមុនយើង ហើយច្រើនជាងយើងទៅទៀត។ ការឈរមាំសម្រាប់ព្រះគឺតែងតែទទួលបានរង្វាន់ តែវាមិនតែងតែងាយស្រួលនោះទេ។ តើអ្នកធ្លាប់ប្រឈមមុខជាមួយនឹងកាលៈទេសៈណាមួយ ដែលជាការសាកល្បងណាមួយហើយអ្នកនៅតែឈរមាំខាងព្រះដែរឬទេ? តើអ្នកត្រៀមខ្លួនសម្រាប់ការសាកល្បងនោះហើយឬនៅ? សូមទុកចិត្តលើទ្រង់។ នៅពេលដែលយើងក្រោកឈរសម្រាប់ទ្រង់ ព្រះអង្គនឹងជួយដល់យើងការពារយើង ហើយនឹងផ្តល់រង្វាន់សម្រាប់យើងផងដែរ។ ទ្រង់សព្វព្រះទ័យនៅពេលដែលយើងថ្វាយបង្គំទ្រង់ ហើយទ្រង់គឺមិនដែលមើលរំលងទេ។

**ចំរៀង៖** ១. ព្រះយើងជាព្រះអស្ចារ្យ ២. ព្រះអម្ចាស់យើងល្អណាស់ ៣. ខ្ញុំថ្វាយបង្គំទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «តំរៀបឱ្យត្រូវ»**




**សម្ភារៈដែលត្រូវការ៖** ស្បែកជើង៣គូរខុសៗគ្នា ប្រអប់មួយ

១. ឲ្យកុមារឈរជាជួរ។

២. គ្រូនឹងដាក់ស្បែកជើងម្ខាងនៃស្បែកជើងទាំង៣គូរនៅក្នុងប្រអប់មួយ ដោយមិនឲ្យកុមារដឹងនោះទេ។

៣. កុមារម្នាក់ៗត្រូវដើរទៅកាន់ប្រអប់ម្នាក់ម្តង ហើយគេត្រូវព្យាយាមដាក់ស្បែងជើងឲ្យត្រូវតាមគូរបស់វានៅក្នុងប្រអប់ (ដោយមិនដឹងពីលំដាប់លំដោយដែលគ្រូបានដាក់នោះទេ។)



៤. នៅពេលដែលកុមារអស់ចិត្តហើយគ្រូនឹងប្រាប់កុមារថាគេដាក់ត្រូវ ឬខុស

៥. ប្រសិនបើកុមារដាក់ត្រូវតាមលំដាប់លំដោយនោះគេនឹងឈ្នះល្បែងនេះ តែបើគេដាក់មិនត្រូវទេនោះ គេនឹងចាញ់ល្បែងនេះ។

៦. ប្រសិនបើកុមារណាម្នាក់ដាក់ត្រូវតាមលំដាប់លំដោយ គ្រូត្រូវប្តូរទីតាំងស្បែកជើងនោះសម្រាប់កុមារបន្ទាប់។ លេងល្បែងនេះរហូតដល់កុមារ

បានលេងគ្រប់ៗគ្នា។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា បើទោះបីជាពួកគេមិនបានដឹងពីលំដាប់លំដោយស្បែកជើងនៅក្នុងប្រអប់ក៏ដោយ ក៏មានកុមារខ្លះអាចដាក់ត្រូវតាមលំដាប់លំដោយនោះដែរ។ ក៏ដូចគ្នានេះដែរ ប្រសិនបើយើងនៅជាប់ជាមួយព្រះ ទ្រង់នឹងជួយដល់យើងឲ្យឆ្លងកាត់ឧបសគ្គទាំងអស់នោះបាន។

## ៤. ការណែនាំមេរៀន

តើអ្នកតែងតែធ្វើការជ្រើសរើសត្រឹមត្រូវជានិច្ចដែរឬទេ? តើមានពេលណាមួយដែលអ្នកមិនចង់ជ្រើសរើសធ្វើអ្វីដែលត្រឹមត្រូវទេ? មានពេលខ្លះយើងជ្រើសរើសធ្វើអ្វីមួយ ទោះបីជាយើងមិនចង់ធ្វើក៏ដោយ។ នៅពេលដែលអ្នកជ្រើសរើសធ្វើនូវរឿងដ៏ត្រឹមត្រូវ មិនខ្វល់ថាអ្នកមានអារម្មណ៍បែបណានោះទេ តែអ្នកបានធ្វើឲ្យព្រះសព្វព្រះហឫទ័យ។ ព្រះជាម្ចាស់ផ្តល់សង្ឃឹម និងជួយយើងឲ្យធ្វើអំពើល្អ ទោះបីវាយ៉ាងលំបាកក៏ដោយ។ ថ្ងៃនេះយើងនឹងរៀនពីមិត្តសំលាញ់បីនាក់បានជ្រើសរើសធ្វើនូវរឿងត្រឹមត្រូវ បើទោះបីជារឿងនោះគម្រាមកំហែងដល់ជីវិតពួកគេក៏ដោយ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះយើងនឹងរៀនពីរបៀបដែលព្រះជួយយើងឲ្យធ្វើនូវរឿងដ៏ត្រឹមត្រូវបើទោះបីជាវាពិបាកធ្វើក៏ដោយ។ រឿងនៅក្នុងព្រះគម្ពីរដែលបង្ហាញនេះគឺទាក់ទងទៅនឹង សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ។ តើអ្នកធ្លាប់បានលឺឈ្មោះពួកគេដែលឬទេ? តោះនិយាយតាមខ្ញុំ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ។

ពួកគាត់ទាំងបីនាក់គឺជាមិត្តភក្តិរបស់ដានីយ៉ែល។ ពួកគេត្រូវបានចាប់ជាឈ្លើយទៅស្រុកបាប៊ីឡូន ហើយពួកគេត្រូវទៅបម្រើស្តេចនៃស្រុកបាប៊ីឡូន។ ស្តេចនេប៊ូក្នេសាជាស្តេចរបស់បាប៊ីឡូនបានបង្កើតរូបព្រះមួយដ៏ខ្ពស់ ធ្វើពីមាសហើយឲ្យមនុស្សគ្រប់គ្នាថ្វាយបង្គំរូបព្រះនោះ។ មិត្តភក្តិទាំងបីនាក់របស់ដានីយ៉ែលគឺ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ក៏ត្រូវបានគេប្រាប់ឲ្យទៅថ្វាយបង្គំរូបព្រះមាសនោះដែរ ប៉ុន្តែពួកគេទាំងបីនាក់បានបដិសេធ ហើយបន្តថ្វាយបង្គំព្រះពិតតែមួយប៉ុណ្ណោះ។ នេះគឺមិនមែនជាការសម្រេចចិត្តដ៏ងាយស្រួលនោះទេ ពីព្រោះថាពួកគេនឹងត្រូវកាត់ទោសប្រហារជីវិត ប្រសិនបើពួកគេមិនធ្វើតាមរាជបញ្ជារបស់ស្តេច។ ស្តេចគឺខឹងជាខ្លាំងហើយបានបញ្ជាឲ្យទាហានចងពួកគេឲ្យជាប់រួចបោះចូលទៅក្នុងគុកភ្លើង។ គុកភ្លើងនោះគឺពិតជាក្តៅខ្លាំងណាស់ សូម្បីតែអ្នកដែលបោះ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ក៏ត្រូវបានស្លាប់ដោយសារអណ្តាតភ្លើងដែរ។

ប៉ុន្តែនៅពេលដែលស្តេចមើលទៅក្នុងគុកភ្លើង គាត់បានឃើញបុរស៤នាក់កំពុងដើរនៅក្នុងភ្លើងនោះឥតមានជាប់ចំណង ហើយក៏មិនមានគ្រោះថ្នាក់អ្វីទាំងអស់! ព្រះគម្ពីរមិនបាននិយាយថា បុគ្គលទី៤នោះគឺជានរណានោះទេ ប៉ុន្តែប្រហែលជាទេវតា ឬអាចជាព្រះយេស៊ូវក៏ថាបាន។ នៅពេលដែលសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោដើរចេញពីភ្លើងគឺពួកគេមិនមានរលាកអ្វីបន្តិចសោះ សូម្បីតែខោអាវក៏មិនមានក្លិនផ្សែង ហើយក៏មិនមានសញ្ញាបញ្ជាក់ថា ពួកគេត្រូវភ្លើងឆេះអ្វីទាំងអស់! ពេលនោះស្តេចក៏បានដឹងថា ព្រះរបស់ពួកគេគឺជាព្រះពិតតែមួយ។

ការជ្រើសរើសក្នុងការថ្វាយបង្គំព្រះពិតតែមួយ មិនមែនជារឿងងាយស្រួលនោះទេសម្រាប់មិត្តភក្តិទាំងបីនាក់នោះ។ ប៉ុន្តែពួកគេសម្រេចចិត្តក្នុងការស្តាប់បង្គាប់ ព្រះជំនួសឲ្យការស្តាប់តាមស្តេច ហើយពួកគេជឿថាព្រះនឹងជួយ

ពួកគេ។ មានបុគ្គលជាច្រើនទៀតនៅក្នុងព្រះគម្ពីរក៏បានសម្រេចចិត្តធ្វើនូវរឿងត្រឹមត្រូវ បើទោះបីជាវាផ្តល់ផលពិបាកដល់ពួកគេក៏ដោយ។

ម៉ូសេបានសម្រេចចិត្តនាំជនជាតិអ៊ីស្រាអែលចេញពីអេហ្ស៊ីប បើទោះបីជាគាត់ដឹងថាគាត់ត្រូវបាត់បង់គ្រួសារ និងទ្រព្យសម្បត្តិទាំងអស់ដែលគាត់មាននៅអេហ្ស៊ីបក៏ដោយ។ អេសធើបានស្នើសុំឲ្យស្តេចសង្គ្រោះប្រជាជនរបស់នាង បើទោះបីជានាងដឹងថាស្តេចនឹងខឹងហើយអាចសម្លាប់នាងក៏ដោយ។ ពួកសិស្សរបស់ព្រះយេស៊ូវបានប្រាប់មនុស្សផ្សេងទៀតអំពីព្រះយេស៊ូវ បើទោះបីជាពួកគេដឹងថាមនុស្សទាំងនោះអាចនឹងសើចចំអកឲ្យពួកគាត់ បដិសេធ ឬប្រឈមមុខនឹងសេចក្តីស្លាប់ក៏ដោយ។ ពួកគេបានជ្រើសរើសធ្វើនូវរឿងត្រឹមត្រូវ ដោយមិនខ្វល់ពីអ្វីទាំងអស់។ នេះគឺជាជំនឿ!

ព្រះគឺពិតជាល្អខ្លាំងណាស់សម្រាប់ពួកយើងពីព្រោះទ្រង់បានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធឲ្យមកជួយដល់ពួកយើង! ទ្រង់មិនចង់ឲ្យយើងធ្វើកិច្ចការនោះតែម្នាក់ឯងនោះទេ។ ដូច្នេះនៅពេលដែលយើងមានអារម្មណ៍ថា មិនចូលចិត្តអ្វីមួយ នៅពេលដែលអ្នកមានការភ័យខ្លាច ឬប្រឈមមុខនឹងសេចក្តីស្លាប់ក៏ដោយ ក៏ព្រះវិញ្ញាណបរិសុទ្ធនឹងជួយដល់អ្នកឲ្យឈរមាំសម្រាប់ព្រះអង្គ ហើយធ្វើនូវអ្វីដែលត្រឹមត្រូវដោយមិនខ្វល់ពីអ្វីទាំងអស់។ ទ្រង់នឹងជួយអ្នកឲ្យរឹងមាំ!

## ៦. សំនួរពិភាក្សា

១. តើមិត្តភក្តិទាំងបីនាក់នោះមានឈ្មោះអ្វីខ្លះ? *សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ*

២. ហេតុអ្វីបានជាស្តេច នេប៊ូក្នេសា ជាស្តេចរបស់បាប៊ីឡូនខឹងនឹងពួកគេ?
*ពួកគេបដិសេធមិនថ្វាយបង្គំរូបព្រះដែលស្តេចបានបង្កើត ហើយនៅបន្តថ្វាយបង្គំព្រះពិតតែមួយ*

៣. តើអ្វីគឺជាការដាក់ទោសសម្រាប់មិត្តភក្តិទាំងបី? *បោះចូលទៅក្នុងគុកភ្លើង*

៤. តើស្តេចនេប៊ូក្នេសាដឹងថាព្រះបានជួយសង្គ្រោះដល់មិត្តភក្តិទាំងបីដោយរបៀបណា?
*ទ្រង់បានឃើញបុរស៤នាក់ដើរចេញពីគុកភ្លើង ប៉ុន្តែគឺមានតែបុរស៣នាក់ប៉ុណ្ណោះដែលបានបោះចូលទៅ ហើយពួកគេគឺមិនមានស្នាមភ្លើងឆេះអ្វីទាំងអស់នៅពេលដែលពួកគេចេញមកវិញ*

៥. តើនរណាដែលនឹងជួយយើងឲ្យធ្វើនូវរឿងត្រឹមត្រូវនៅក្នុងជីវិត? *ព្រះនឹងតែងតែជួយដល់យើង*

## ៧. ល្បែងកំសាន្ត «រទេះភ្លើង»

ក្បាលរទេះភ្លើង



១. ឲ្យកុមារឈរជាជួរហើយតោងចង្កេះគ្នា។

២. គ្រូត្រូវឈរនៅខាងមុខគេធ្វើជាក្បាលរទេះភ្លើង។

៣. កុមារត្រូវតោងគ្នាឲ្យជាប់ ហើយធ្វើកាយវិការតាមគ្រូ។ គ្រូអាចរំលងកៅអី លូនក្រោមតុ ហើយផ្លាស់ទីទៅឆ្វេងឬទៅស្តាំ។ល។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា បើទោះបីជាពួកគេធ្វើតាមគ្រូក៏ដោយ ក៏ពួកគេនៅតែមានការពិបាក។ នៅពេលដែលយើងដើរតាមព្រះយើងក៏នៅតែមានពេលពិបានដូចគ្នា។ ប៉ុន្តែយើងត្រូវតែមានជំនឿ និងទុកចិត្តលើព្រះ ដូច្នេះព្រះនឹងតែងតែជួយដល់យើងឲ្យធ្វើនូវរឿង

ត្រឹមត្រូវបើទោះបីជាវាពិបាកក៏ដោយ។

**៨. ខគម្ពីរចងចាំ** រ៉ូម១២:២១

**៩. ហត្ថកម្ម** ផាត់ពណ៌រូបភាព «មិត្តភក្តិរបស់ដានីយ៉ែលគេចផុតពីគុកភ្លើងយ៉ាងសន្ទោរសន្ទៅ»

**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហត្ថកម្ម

១. សូមពន្យល់កុមារពីរឿងនៅក្នុងព្រះគម្ពីរម្តងទៀតដោយប្រើប្រាស់ក្រដាសរូបភាព២សន្លឹក ហើយឲ្យកុមារសរសេរនូវខគម្ពីរចងចាំ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

## មិត្តភក្តិរបស់ដានីញ៉ែលគេចផុតពីគុកភ្លើងយ៉ាងសន្ធោសន្ធៅ





សូមសរសេរខគម្ពីរចងចាំ: ____________________________________

____________________________________________________